**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៧៧០ អបស/ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១១

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រកាសលេខ ០៣១៤ អបស.ឱអបស ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១០ របស់ក្រសួងសុខាភិបាល ស្តីពី បែបបទ និងល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយគ្រឿងសម្អាង

## រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញ ព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្ម ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញ អនុក្រឹត្យលេខ ១២២អក្រ.បក ចុះថ្ងៃទី ២៨ សីហា ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង
- បានឃើញ ប្រកាសលេខ ០៣១៤ អបស.ឱអបស ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១០ របស់ក្រសួងសុខាភិបាល ស្តីពី បែបបទ និងល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយគ្រឿងសម្អាង
- និងយោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## <u>ស ម្រេ ច</u>

**<u>ប្រការ១</u> :** ខ្លឹមសារប្រកាសលេខ ០៣១៤ អបស.ឱអបស ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១០ របស់ក្រសួងសុខាភិបាល ត្រូវបានកែសម្រួលដូចខាងក្រោម ។

**<u>ប្រការ២</u> :** ការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងសម្អាងគ្រប់ប្រភេទ តាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តិប័ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ ប័ណ្ណប្រកាសរូបភាព សិក្ខាសាលា ទិវាវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ ឬតាមមធ្យោបាយផ្សេងៗទៀតអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៥/៤២៦ ៨៤១ ទូរស័ព្ទ:(៨៥៥-២៣) ៧២២ ៩៣៣

**ប្រការ៣ :** គ្រឿងសម្អាងគ្រប់ប្រភេទ អាចសុំធ្វើការផ្សព្វផ្សាយបាន លុះត្រាតែមានលេខបញ្ជិកាទំនិញ លេខប្រវេទនីចេញដោយក្រសួងសុខាភិបាល ។

អត្ថបទ និងរូបភាពដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងសម្អាង ត្រូវឆ្លងការត្រួតពិនិត្យ និងមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ៤ :** ការសុំផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងសម្អាង ត្រូវបំពេញសំណុំលិខិត ដូចខាងក្រោម :

**ក -ករណីផ្សព្វផ្សាយតាមទូរទស្សន៍ ឬវិទ្យុ**

| | |
|---|---|
| -ពាក្យសុំផ្សព្វផ្សាយ និង កិច្ចសន្យា | ១ ច្បាប់ ( មានគំរូ) |
| -វិញ្ញាបនបត្រប្រវេទនី (ថតចម្លង) | ១ ច្បាប់ |
| -សេចក្តីព្រាងអត្ថបទផ្សព្វផ្សាយ | ១ ច្បាប់ |
| -កាសែតវីដេអូ **DVD** ឬ **VCD** ឬ **CD** ជា **Spot** គំរូ | ១ ឯកតា |
| -គ្រឿងសម្អាងគំរូ | ១ ឯកតា |

**ខ -ករណីផ្សព្វផ្សាយតាមសារព័ត៌មាន ឬទស្សនាវដ្តី ឬប្រតិទិន ឬសៀវភៅផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬប័ណ្ណប្រកាសរូបភាព ឬខិត្តប័ណ្ណ ឬសម្ភារៈប្រើប្រាស់ផ្សេងៗ ឬមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ**

| | |
|---|---|
| -ពាក្យសុំផ្សព្វផ្សាយ និង កិច្ចសន្យា | ១ ច្បាប់ ( មានគំរូ) |
| -វិញ្ញាបនបត្រប្រវេទនី (ថតចម្លង) | ១ ច្បាប់ |
| -សេចក្តីព្រាងអត្ថបទ និងរូបភាពផ្សព្វផ្សាយ | ១ ច្បាប់ |
| -គ្រឿងសម្អាងគំរូ | ១ ឯកតា |

**គ -ករណីធ្វើសិក្ខាសាលា ឬប្រជុំតុមូល ឬក្នុងកម្មវិធីផ្សេងៗតាមប៉ុស្តិ៍ វិទ្យុ ទូរទស្សន៍**

| | |
|---|---|
| -ពាក្យសុំផ្សព្វផ្សាយ និងកិច្ចសន្យា | ១ ច្បាប់ ( មានគំរូ) |
| -វិញ្ញាបនបត្រប្រវេទនី (ថតចម្លង) | ១ ច្បាប់ |
| -កម្មវិធី | ១ ច្បាប់ |

**ប្រការ៥ :** លិខិតអនុញ្ញាតផ្សព្វផ្សាយតាម :

-ប្រតិទិន ឬខិត្តប័ណ្ណ ឬសៀវភៅផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬសម្ភារៈប្រើប្រាស់ផ្សេងៗ មានសុពលភាពរយៈពេល ១ឆ្នាំ

-វិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ឬទស្សនាវដ្តី ឬប័ណ្ណប្រកាសរូបភាព ឬមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ មានសុពលភាពរយៈពេល ៦ខែ

-ការធ្វើសិក្ខាសាលា ឬប្រជុំតុមូល ឬក្នុងកម្មវិធីផ្សេងៗតាមប៉ុស្តិ៍វិទ្យុ ទូរទស្សន៍ មានសុពលភាពរយៈពេល ៣ខែ

-សាមីជនអាចសុំបន្តការផ្សព្វផ្សាយសារឡើងវិញ ១ខែមុនពេលអស់សុពលភាព ។

**ប្រការ៦** : ការផ្សព្វផ្សាយដែលត្រូវហាមឃាត់ :

-ការប្រើប្រាស់ពាណិជ្ជនាម រូបភាពដែលប៉ះពាល់ដល់វប្បធម៌ជាតិ ឬអត្ថបទ រចនាប័ទ្មក្នុងគោលបំណងបំផ្លើស អំពីគុណភាពគ្រឿងសម្អាង

-តាមមធ្យោបាយ ឬរូបភាពផ្សេងៗទៀត ដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ករណីលិខិតអនុញ្ញាតផ្សព្វផ្សាយអស់សុពលភាព ។

**ប្រការ៧** : ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញនូវលិខិតអនុញ្ញាតផ្សព្វផ្សាយ ក្នុងករណីពិនិត្យឃើញថា :

-ខ្លឹមសារ ឬរូបភាព ឬមធ្យោបាយផ្សព្វផ្សាយមានលក្ខណៈខុសពីការយល់ព្រមរបស់ក្រសួងសុខាភិបាល

-ឬផលិតផលនោះបង្ក ឬអាចបង្កគ្រោះថ្នាក់ដល់សុខភាពតាមការផ្តល់ព័ត៌មានពីក្រសួងមានសមត្ថកិច្ច ។

**ប្រការ៨** : ការប្រព្រឹត្តល្មើសនឹងប្រកាសនេះត្រូវផ្តន្ទាទោសតាមទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងឱសថ។

**ប្រការ៩** : អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋាន នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង មានភារកិច្ចត្រួតពិនិត្យតាមដានការអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងខ្លួន ។

**ប្រការ១០** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១១** : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**កន្លែងទទួល** :

-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួងទំនាក់ទំនងសភា-ព្រឹទ្ធសភា និងអធិការកិច្ច
"ដើម្បីជ្រាបជាព័ត៌មាន និង សហការ"
-ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
-សាលារាជធានី-ខេត្ត "ដើម្បីជ្រាបជាព័ត៌មាន និង សហការ"
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-លេខាធិការដ្ឋានគណៈកម្មការអន្តរក្រសួងនិងគណៈកម្មការរាជធានី និងខេត្ត
លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
-មន្ទីរសុខាភិបាលរាជធានី-ខេត្ត
"ដើម្បីអនុវត្ត"
-ឯកសារ
-កាលប្បវត្តិ

ក្រសួងសុខាភិបាល

ម៉ម_ប៊ុនហេង